# ព្រះរាជក្រម

នស/រកម/០៦០៦/០១៨

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី ៤ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាពុំមានលទ្ធភាពពិនិត្យ និងផ្តល់យោបល់លើអត្ថបទច្បាប់នេះ បានទាន់ពេលវេលាស្របតាមមាត្រា១១៣ថ្មីនៃរដ្ឋធម្មនុញ្ញ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់

# ស្តីពី

# ការគ្រប់គ្រងរោងចក្រ

# និងសិប្បកម្ម

# ជំពូកទី ១

# បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានវិសាលភាពចំពោះរោងចក្រ និងសិប្បកម្មទាំងអស់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ដែលស្ថិតនៅក្រោមសមត្ថកិច្ចដឹកនាំ និងគ្រប់គ្រងរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដោយមិនប៉ះពាល់ដល់សមត្ថកិច្ចរបស់ក្រសួងស្ថាប័នផ្សេងទៀតដែលពាក់ព័ន្ធ ។

**មាត្រា ២.-**

រោងចក្រ និងសិប្បកម្មដែលមានចែងនៅក្នុងច្បាប់នេះ សំដៅទៅលើអគារ ទីកន្លែង ឬ យានយន្ត សម្រាប់ផលិត បំប្លែងវត្ថុធាតុដើម ឬ ផលិតផលពាក់កណ្តាលសម្រេចឱ្យទៅជាផលិតផលថ្មី ឬ/និង សម្រាប់ធ្វើសកម្មភាពផ្សេងទៀត ដែលមានជាអាទិ៍ ផ្គុំ ដំឡើង ជួសជុល ធ្វើតេស្ត វេចខ្ចប់ ច្រកបំពេញ ថែទាំ រក្សាទុក កែលម្អ ដើម្បីបម្រើសេចក្តីត្រូវការទីផ្សារ ។

**មាត្រា ៣.-**

រោងចក្រ និងសិប្បកម្មដែលស្ថិតក្រោមសមត្ថកិច្ចដឹកនាំ និងគ្រប់គ្រងរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល មានដូចខាងក្រោម៖

១-ផ្នែកស្បៀង ម្ហូបអាហារ ភេសជ្ជៈ និងថ្នាំជក់

២-ផ្នែកវាយនភ័ណ្ឌ សំលៀកបំពាក់ និងផលិតផលអំពីស្បែក

៣-ផ្នែកផលិតផលក្រដាស

៤-ផ្នែក គីមី ផលិតផលពីកៅស៊ូ ផ្លាស្ទិច លើកលែងតែឧស្សាហកម្មប្រេងកាត និងឧស្ម័ន

៥-ផ្នែកផលិតផលពីរ៉ែអលោហៈ

៦-ផ្នែកលោហៈមូលដ្ឋាន

៧-ផ្នែកកែច្នៃលោហៈ ម៉ាស៊ីន និង គ្រឿងបរិក្ខារ

៨-ផ្នែកផ្សេងទៀតមានជាអាទិ៍ ផលិតគ្រឿងអលង្ការ រតនភ័ណ្ឌ និងលម្អ ឧបករណ៍សិល្បៈ កីឡា ក្មេងលេង និងសម្ភារៈការិយាល័យ ។

## ជំពូកទី ២
## ការបង្កើត និងកិច្ចដំណើរការ
### ផ្នែកទី ១
### រោងចក្រ

**មាត្រា ៤.-**

ការបង្កើតរោងចក្រដែលមានចែងក្នុងមាត្រា ៣ ត្រូវមានប្រកាសអនុញ្ញាតពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដោយមានយោបល់ឯកភាពពីក្រសួងស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធ ។ ការបង្កើតរោងចក្រផ្តោតសំខាន់ទៅលើ :

-ការរៀបចំ ទីកន្លែង ឬ/និង ការសាងសង់អគារ សម្រាប់ដំណើរការរោងចក្រ

-ការសាងសង់អគារ សម្រាប់បំពាក់ម៉ាស៊ីន ដើម្បីដំណើរការរោងចក្រ

-ការបំពាក់ម៉ាស៊ីន ក្នុងអគារ ទីកន្លែង ឬយានយន្ត សម្រាប់ដំណើរការរោងចក្រ

-វត្ថុធាតុដើមសម្រាប់ដំណើរការរោងចក្រ ។

**មាត្រា ៥.-**

ម្ចាស់រោងចក្រត្រូវស្ថិតនៅក្រោមច្បាប់នេះ ហើយអាចជារូបវន្តបុគ្គល ឬនីតិបុគ្គល ។ ម្ចាស់រោងចក្រអាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឱ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ប៉ុន្តែក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់និងអ្នកប្រើប្រាស់ ។

**មាត្រា ៦.-**

ការត្រួតពិនិត្យគុណភាព ការកំណត់ស្តង់ដា ការចុះបញ្ជី និងសញ្ញាបញ្ជាក់ផលិតផលត្រូវអនុវត្តតាមច្បាប់ដែលមានជាធរមាន ។

**មាត្រា ៧.-**

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវផ្តល់លិខិតបញ្ជាក់ផ្សេងៗពាក់ព័ន្ធនិងផលិតកម្មតាមការស្នើសុំរបស់ម្ចាស់រោងចក្រ បើពិនិត្យឃើញថាជាការចាំបាច់ ។

**មាត្រា ៨.-**

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវឆ្លើយតបអំពីការសម្រេចរបស់ខ្លួនទៅអ្នកសុំបង្កើតរោងចក្រ ក្នុងរយៈពេល ៧ (ប្រាំពីរ)ថ្ងៃ យ៉ាងយូរនៃថ្ងៃធ្វើការ គិតពីថ្ងៃទទួលពាក្យសុំដែលបានបំពេញបែបបទគ្រប់គ្រាន់ និងត្រឹមត្រូវ ។

ក្នុងករណីមិនយល់ព្រមលើពាក្យសុំបង្កើតរោងចក្រ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវពន្យល់ហេតុផលលើការសម្រេចរបស់ខ្លួនឱ្យបានច្បាស់លាស់ ។

**មាត្រា ៩.-**

មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងទៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពលឱ្យបានមុនរយៈពេល ១៥ (ដប់ប្រាំ)ថ្ងៃ យ៉ាងតិច ។

**មាត្រា ១០.-**

ក្នុងការបង្កើតនិងកិច្ចដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវប្រើប្រាស់វិស្វករ ឬ អ្នកបច្ចេកទេស ដែលមានសញ្ជាតិខ្មែរជាអាទិភាព ។ ល័ក្ខខ័ណ្ឌនៃការប្រើប្រាស់វិស្វករ អ្នកបច្ចេកទេសបរទេស ត្រូវអនុវត្តតាមច្បាប់ដែលមានជាធរមាន ។

**មាត្រា ១១.-**

ក្នុងការពង្រីក ឬ ការបង្កើតសាខា ឬ ការផ្លាស់ប្តូរទីតាំងរោងចក្រត្រូវតែមានលិខិតអនុញ្ញាតពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**មាត្រា ១២.-**

ការពង្រីករោងចក្រ គឺជាការបង្កើនសមត្ថភាពផលិតកម្មលើសពី ២០ (ម្ភៃ) ភាគរយ នៃសមត្ថភាពដើម ដោយ ៖

១-ការបង្កើនចំនួនម៉ាស៊ីន ឬ ការផ្លាស់ប្តូរម៉ាស៊ីន

២-ការរុះរើដើម្បីរៀបចំ ឬ ការពង្រីក ឬ ការសាងសង់អគារ

៣-ការផ្លាស់ប្តូរមុខផលិតផល ឬ បន្ថែមមុខផលិតផល

៤-ការពង្រីកបរិវេណរោងចក្រ ។

ការបង្កើតសាខារោងចក្រ គឺជាការបង្កើតមូលដ្ឋានផលិតកម្មថ្មី ដែលធ្វើផលិតកម្មបម្រើឱ្យរោងចក្រដើម ។

ការផ្លាស់ប្តូរទីតាំង គឺការផ្លាស់ប្តូររោងចក្រពីទីតាំងចាស់ទៅទីតាំងថ្មី ។

**មាត្រា ១៣.-**

ក្នុងករណីប្តូរម្ចាស់រោងចក្រ ម្ចាស់រោងចក្រថ្មី ត្រូវធ្វើពាក្យសុំការទទួលស្គាល់ជាម្ចាស់រោងចក្រពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងរយៈពេល ១០ (ដប់)ថ្ងៃ នៃថ្ងៃធ្វើការយ៉ាងយូរ ចាប់ពីថ្ងៃដែលខ្លួនបានទទួលសិទ្ធិជាម្ចាស់រោងចក្រថ្មី ។ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវឆ្លើយតបទៅម្ចាស់រោងចក្រវិញក្នុងរយៈពេល ០៥ថ្ងៃ នៃថ្ងៃធ្វើការ ចាប់ពីថ្ងៃទទួលពាក្យសុំ ។

**មាត្រា ១៤.-**

ក្នុងករណីដែលម្ចាស់រោងចក្រទទួលមរណភាព ឬ អសមត្ថភាពតាមផ្លូវច្បាប់ អ្នកដែលទទួលសិទ្ធិគ្រប់គ្រងបន្តស្របច្បាប់ ត្រូវធ្វើពាក្យសុំការទទួលស្គាល់ជាម្ចាស់រោងចក្រពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងរយៈពេល ៤៥ (សែសិបប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការយ៉ាងយូរ គិតចាប់ពីថ្ងៃដែលម្ចាស់រោងចក្រដើមទទួលមរណភាព ឬ បាត់បង់សមត្ថភាពតាមផ្លូវច្បាប់ ។

អ្នកទទួលសិទ្ធិគ្រប់គ្រងបន្ត អាចដំណើរការរោងចក្រជាបណ្តោះអាសន្នបានរហូតមានការទទួលស្គាល់ជាម្ចាស់រោងចក្រពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**មាត្រា ១៥.–**

ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រយៈពេល ១(មួយ)ខែ យ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ។

ក្រៅពីករណីប្រធានសក្តិ ការផ្អាកដំណើរការរោងចក្រជាប់ៗគ្នាក្នុងរយៈពេល ១២(ដប់ពីរ)ខែ ត្រូវចាត់ទុកថាជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ។ ក្នុងករណីនេះ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវចេញប្រកាសលុបប្រកាសអនុញ្ញាតបង្កើតរោងចក្រ ។

**មាត្រា ១៦.–**

ម្ចាស់រោងចក្រត្រូវតាំងបង្ហាញ ប្រកាសបង្កើតរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយជាចំហនៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ។

**មាត្រា ១៧.–**

ក្នុងករណីដែលប្រកាសបង្កើតរោងចក្រ ឬ/និង លិខិតអនុញ្ញាតទាំងឡាយ ត្រូវបានបាត់បង់ដោយប្រការណាមួយ ម្ចាស់រោងចក្រត្រូវធ្វើពាក្យសុំប្រកាស ឬ លិខិតជំនួសមួយទៀតពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងរយៈពេលយ៉ាងយូរបំផុត ១៥(ដប់ប្រាំ)ថ្ងៃ គិតពីថ្ងៃដែលបានបាត់បង់ ។

**មាត្រា ១៨.–**

រោងចក្រនីមួយៗ ត្រូវមានឈ្មោះរោងចក្រ ហើយផ្លាកឈ្មោះត្រូវសរសេរជាអក្សរខ្មែរ មានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត ។ ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន នៅកន្លែងដែលងាយមើលឃើញ នៅខាងមុខរោងចក្រ ។

ការផ្លាស់ប្តូរឈ្មោះរោងចក្រ ត្រូវតែមានការយល់ព្រមពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

4

**មាត្រា ១៩.-**

ម្ចាស់រោងចក្រត្រូវផ្តល់ឱ្យបានត្រឹមត្រូវនូវទិន្នន័យ និងរបាយការណ៍ចាំបាច់នានាតាមការកំណត់របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**មាត្រា ២០.-**

ម្ចាស់រោងចក្រដែលមិនស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវធ្វើការចុះបញ្ជីរោងចក្រនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងត្រូវផ្តល់ទិន្នន័យ និងរបាយការណ៍ ដូចមានចែងក្នុងមាត្រា ១៩ ។

**មាត្រា ២១.-**

ទិន្នន័យ និងរបាយការណ៍ ដែលរោងចក្រផ្តល់ជូនក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល គឺជាការសម្ងាត់វិជ្ជាជីវៈរបស់រោងចក្រ ។ ទិន្នន័យ និងរបាយការណ៍ទាំងនេះមិនត្រូវបានយកទៅផ្សព្វផ្សាយជាសាធារណៈឡើយ បើគ្មានការយល់ព្រមពីម្ចាស់រោងចក្រ ។

**មាត្រា ២២.-**

ម្ចាស់រោងចក្រ ដែលស្ថិតនៅក្រោមច្បាប់នេះ មានកាតព្វកិច្ចបង់ប្រាក់កម្រៃសេវាកម្មស្របតាមការកំណត់នៃប្រកាសរួមរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ផ្នែកទី ២
## សិប្បកម្ម

**មាត្រា ២៣.-**

សិប្បកម្មត្រូវបានអនុញ្ញាតឱ្យបង្កើតនិងដំណើរការ ដោយម្ចាស់សិប្បកម្មត្រូវធ្វើការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអាជ្ញាធរមូលដ្ឋាន និងធ្វើការចុះបញ្ជីនៅមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្ត-ក្រុង ដែលខ្លួនបោះទីតាំងក្នុងរយៈពេលយ៉ាងយូរ ៧២(ចិតសិបពីរ) ថ្ងៃ ក្រោយថ្ងៃដំណើរការ លើកលែងតែប្រភេទសិប្បកម្មដែលមានកំណត់ដោយប្រកាស

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដែលត្រូវសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល មុនដំណើរការ ។

បែបបទនៃការបង្កើតនិងកិច្ចដំណើរការ សិប្បកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

## ជំពូកទី ៣

## សុវត្ថិភាពឧស្សាហកម្ម

**មាត្រា ២៤.-**

ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេសដែលត្រូវបាន កំណត់ដោយប្រកាសរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ជនណាដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬ ចាត់ឱ្យមករៀបចំរោងចក្រ បានឡើយ ។

**មាត្រា ២៥.-**

គ្រប់ផ្នែកនៅក្នុងរោងចក្រត្រូវធានានិងរក្សាឱ្យមានពន្លឺគ្រប់គ្រាន់ និងខ្យល់ចេញចូល បរិបូរណ៍ ត្រូវធានានូវភាពគ្មានគ្រោះថ្នាក់ដែលជាអាទិ៍បណ្តាលមកពី វិទ្យុសកម្ម សំឡេង ញ័រ ពន្លឺ កាំរស្មី ក្លិន ចំហាយ កំដៅ ផ្សែង ធូលី និង ភាពកខ្វក់ផ្សេងៗទៀត ។

**មាត្រា ២៦.-**

រោងចក្រត្រូវតែមានប្រព័ន្ធបង្ការអគ្គីភ័យ ដែលរួមមាន :

១-ប្រព័ន្ធប្រកាសភាពអាសន្ន និង មធ្យោបាយសម្រាប់ពន្លត់អគ្គីភ័យ

២-សញ្ញាប្រយ័ត្នអគ្គីភ័យ នៅកន្លែងដែលចាំបាច់

៣-ទ្វារសង្គ្រោះយ៉ាងតិចបំផុតមានចំនួនពីរ នៅតាមជាន់នីមួយៗ

៤-ផ្លូវសង្គ្រោះ សម្រាប់រថយន្តពន្លត់អគ្គីភ័យ

៥-មធ្យោបាយរំដោះខ្លួនផ្សេងៗទៀត

៦-ឬង់បំភ្លឺញសម្រាប់ជម្លៀសខ្លួនពេលមានអាសន្ន ។

**មាត្រា ២៧.-**

ម៉ាស៊ីន ឬ ផ្នែកនៃម៉ាស៊ីន ដែលអាចបង្កឱ្យមានគ្រោះថ្នាក់បានជាយថាហេតុ ត្រូវមានគម្រប ឬ ឧបករណ៍ការពារ ។ ផ្នែកនៃរោងចក្រ ដែលមានគ្រោះថ្នាក់ខ្លាំងត្រូវធ្វើរបាំងព័ទ្ធជុំវិញ ។

**មាត្រា ២៨.-**

ត្រូវមានសញ្ញាបង្ហាញប្រាប់ប្រយ័ត្នគ្រោះថ្នាក់ ឬ បំរាមនៅកន្លែងដែលមានគ្រោះថ្នាក់ ។

**មាត្រា ២៩.-**

ការប្រើប្រាស់ជាតិផ្ទុះ គ្រឿងឆេះ ជាតិពុល គីមីគ្រោះថ្នាក់ ឬ ឧស្ម័ន ក្នុងផលិតកម្ម ត្រូវប្រតិបត្តិទៅតាមលក្ខណៈបច្ចេកទេស ដែលធានាបាននូវសុវត្ថិភាព ។

**មាត្រា ៣០.-**

ឡចំហាយ ប្រព័ន្ធប្រើប្រាស់ចំហាយ ឧបករណ៍ ឬ ធុងដែលប្រើសម្ពាធខ្ពស់ ត្រូវមានការត្រួតពិនិត្យពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលមុននឹងអនុញ្ញាតឱ្យដំណើរការ ។ នៅពេលដំណើរការ ការត្រួតពិនិត្យឧបករណ៍ខាងលើនេះ ត្រូវធ្វើឡើងតាមដំណាក់កាលដែលកំណត់ដោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**មាត្រា ៣១.-**

សំណល់ឧស្សាហកម្មគ្រប់ប្រភេទ មុននឹងបញ្ចេញចោល ត្រូវឆ្លើយតបទៅនឹងកម្រិតបទដ្ឋាននៃការបញ្ចេញសំណល់ ឬ សារធាតុបំពុល ដែលកំណត់ដោយបទប្បញ្ញត្តិរបស់ស្ថាប័នមានសមត្ថកិច្ច ។

ហាមដាច់ខាតចំពោះការបញ្ចេញចោលសំណល់ឧស្សាហកម្ម ដែលមានជាតិពុល ឬ សារធាតុបំពុលដែលនាំឱ្យកខ្វក់ ឬ ប៉ះពាល់ដល់បរិស្ថាន ដោយមិនបានឆ្លងកាត់ប្រព្រឹត្តិកម្មជាមុន ។

ចំពោះសំណល់ឧស្សាហកម្ម ដែលត្រូវយកមកប្រើប្រាស់ឡើងវិញ ត្រូវរក្សាទុកឱ្យបានគត់មត់តាមយថាប្រភេទ និងលក្ខណៈបច្ចេកទេស ។

**មាត្រា ៣២.-**

សំណល់ឧស្សាហកម្មគ្រប់ប្រភេទ ដែលមិនអាចធ្វើប្រព្រឹត្តិកម្មបាន ឬ ដែលបានឆ្លងកាត់ប្រព្រឹត្តិកម្មរួចហើយ តែនៅមានជាតិពុល ឬ មានសារធាតុបំពុលដែលនាំឱ្យកខ្វក់ ឬ ប៉ះពាល់ដល់បរិស្ថាន ឬ មានសារធាតុវិទ្យុសកម្ម មុននឹងបញ្ចេញចោល ឬ ដឹកជញ្ជូនយកទៅកន្លែងដទៃទៀតដើម្បីរក្សាទុក ឬ ដើម្បីគោលបំណងណាមួយផ្សេង ត្រូវមានការត្រួតពិនិត្យ និងមានការអនុញ្ញាតពីស្ថាប័នមានសមត្ថកិច្ច ។

**មាត្រា ៣៣.-**

ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការបញ្ចេញចោល ការសម្អាត និងការទុកដាក់សំណល់ឧស្សាហកម្ម គ្រប់ប្រភេទរបស់រោងចក្រ ។

**មាត្រា ៣៤.-**

ក្នុងការអនុវត្តច្បាប់នេះ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល មានសមត្ថកិច្ចចេញលិខិតបទដ្ឋាន ឬ ស្នើទៅរាជរដ្ឋាភិបាលបង្កើតជាអនុក្រឹត្យ ដើម្បីគ្រប់គ្រងរោងចក្រ ។

## ជំពូកទី ៤
## ការទ្រទ្រង់ និងការលើកទឹកចិត្ត

**មាត្រា ៣៥.-**

ការទ្រទ្រង់ និងការលើកទឹកចិត្តដើម្បីអភិវឌ្ឍរោងចក្រធុនធំ ត្រូវអនុវត្តតាមច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣៦.-**

ចំពោះរោងចក្រធុនមធ្យម តូច និងសិប្បកម្មត្រូវបានអនុញ្ញាតឱ្យមានការទ្រទ្រង់ និងការលើកទឹកចិត្តដោយរាជរដ្ឋាភិបាល ។ ប្រភេទ ទំហំ និងរូបភាពនៃការទ្រទ្រង់ និងការលើកទឹកចិត្ត ត្រូវកំណត់ដោយអនុក្រឹត្យ ។

# ជំពូកទី ៥

# ការត្រួតពិនិត្យ និងអធិការកិច្ចរោងចក្រ

**មាត្រា ៣៧.-**

មន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល មានសិទ្ធិចូលទៅក្នុងរោងចក្រ និងសិប្បកម្ម គ្រប់ម៉ោងធ្វើការរបស់រោងចក្រតាមកាលកំណត់ ឬ មិនតាមកាលកំណត់ ដើម្បីត្រួតពិនិត្យគុណភាព ស្ថានភាព រោងចក្រ ម៉ាស៊ីន មធ្យោបាយនានា ឬ សកម្មភាពផ្សេងៗទៀត ដែលម្ចាស់រោងចក្ររំលោភទៅលើបទប្បញ្ញត្តិនៃច្បាប់នេះ ។ ក្នុងករណីចាំបាច់ ត្រូវធ្វើអធិការកិច្ចរោងចក្រដោយ :

១-យកផលិតផលក្នុងបរិមាណសមស្រប ដើម្បីធ្វើការវិភាគអំពីគុណភាពរួមជាមួយនឹងឯកសារពាក់ព័ន្ធ ។

២-ធ្វើការស្រាវជ្រាវ បញ្ឈប់ ឬ ឃាត់ទុកនូវផលិតផល សម្ភារៈ វត្ថុធាតុដើម និងឯកសារពាក់ព័ន្ធនានា ដែលអាចបណ្ដាលឱ្យមានអន្តរាយដល់មនុស្ស ឬ ដល់ទ្រព្យសម្បត្តិក្នុងរោងចក្រ ឬ ទីជិតខាងរោងចក្របាន ។

៣-សាកសួរ ឬ កោះអញ្ជើញម្ចាស់រោងចក្រ អ្នកគ្រប់គ្រងរោងចក្រ និយោជិត ឬ កម្មករក្នុងរោងចក្រ មកបំភ្លឺព័ត៌មាន ឬ សុំឱ្យផ្ដល់ព័ត៌មាននិងឯកសារ ។

**មាត្រា ៣៨.-**

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលមានសិទ្ធិផ្អាកសកម្មភាពរោងចក្រទាំងឡាយណាដែលបានបង្កើតដោយគ្មានប្រកាសអនុញ្ញាតពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ជាបណ្ដោះអាសន្នក្នុងរយៈពេលមួយមានកំណត់ ដើម្បីតម្រូវឱ្យម្ចាស់រោងចក្រ ឬ អ្នកគ្រប់គ្រងរោងចក្រធ្វើការកែតម្រូវកំហុសរបស់ខ្លួនឡើងវិញ ។

ប្រសិនបើការកែតម្រូវធ្វើឡើងបានត្រឹមត្រូវ និងទាន់ពេលកំណត់ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវចេញប្រកាសអនុញ្ញាតឱ្យបង្កើតរោងចក្រ ។

13/20

ប្រសិនបើការកែតម្រូវមិនបានអនុវត្ត ឬ អនុវត្តមិនត្រឹមត្រូវ ឬ មិនទាន់តាមកាលកំណត់ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល មានសិទ្ធិចេញប្រកាសបិទទ្វាររោងចក្រជាស្ថាពរ ។

បញ្ជាផ្អាកដំណើរការផលិតកម្ម ឬ ប្រកាសបិទទ្វាររោងចក្រជាស្ថាពរ ត្រូវបិទផ្សាយជាសាធារណៈនៅពីមុខរោងចក្រ ឬ ចុះផ្សាយតាមសារព័ត៌មាន ។

**មាត្រា ៣៩.-**

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល មានសិទ្ធិចេញបញ្ជាឱ្យម្ចាស់រោងចក្រ ឬ អ្នកគ្រប់គ្រងរោងចក្រផ្អាកដំណើរការផលិតកម្មទាំងមូល ឬ តាមផ្នែកនៃរោងចក្រជាបណ្តោះអាសន្នក្នុងរយៈពេលមួយមានកំណត់ ដើម្បីឱ្យម្ចាស់រោងចក្រ ឬ អ្នកគ្រប់គ្រងរោងចក្រធ្វើការកែតម្រូវ ឬ កែលម្អឱ្យបានប្រសើរឡើងវិញ ក្នុងករណី :

- មានកំហុសធ្ងន់ធ្ងរផ្នែកបច្ចេកទេស ដូចមានចែងក្នុងមាត្រា ២៤
- កិច្ចដំណើរការផលិតកម្មខុសពីការអនុញ្ញាតរបស់ក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល
- កិច្ចដំណើរការផលិតកម្ម ដែលអាចបណ្តាលឱ្យមានគ្រោះថ្នាក់ដល់មនុស្ស ឬ អន្តរាយដល់ទ្រព្យសម្បត្តិ នៅក្នុងរោងចក្រ ឬ ក្រៅរោងចក្រ
- ម្ចាស់រោងចក្រ ឬ អ្នកគ្រប់គ្រងរោងចក្រ មានចេតនាមិនគោរពតាមលិខិតបញ្ជារបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រសិនបើការកែតម្រូវធ្វើឡើងបានត្រឹមត្រូវនិងទាន់ពេលកំណត់ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវចេញបញ្ជាអនុញ្ញាតឱ្យរោងចក្របន្តដំណើរការផលិតកម្មឡើងវិញ ។

ប្រសិនបើការកែតម្រូវមិនបានអនុវត្ត ឬ អនុវត្តមិនទាន់កាលកំណត់ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល មានអំណាចចេញប្រកាសបិទទ្វាររោងចក្រជាស្ថាពរ ។

បញ្ជាផ្អាកដំណើរការផលិតកម្ម ឬ ប្រកាសបិទទ្វាររោងចក្រជាស្ថាពរ ត្រូវបិទផ្សាយជាសាធារណៈ នៅពីមុខរោងចក្រ ឬ ចុះផ្សាយតាមសារព័ត៌មាន ។

**មាត្រា ៤០.-**

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល មានសិទ្ធិបញ្ជូនលិខិតបញ្ជាទៅកាន់គេហដ្ឋាន ឬរោងចក្ររបស់ម្ចាស់រោងចក្រ ឬ អ្នកគ្រប់គ្រងរោងចក្រ ដែលត្រូវទទួលលិខិតបញ្ជានេះ ដោយផ្ទាល់ ឬ តាមសំបុត្រអនុសិដ្ឋ ដោយមានចុះហត្ថលេខាបានទទួល ។

ក្នុងករណីដែលម្ចាស់រោងចក្រ ឬ អ្នកគ្រប់គ្រងរោងចក្រនោះ បដិសេធមិនព្រមទទួល លិខិតបញ្ជារបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល មានសិទ្ធិអញ្ជើញអាជ្ញាធរ ឬ ភ្នាក់ងារនគរបាលឱ្យចូលរួមជាមួយខ្លួនដើម្បីធ្វើជាសាក្សី ។ បើម្ចាស់រោងចក្រ ឬ អ្នកគ្រប់គ្រងរោងចក្រមិនស្ថិតក្នុងគេហដ្ឋាន ឬ ក្នុងរោងចក្រទេនោះ លិខិតបញ្ជាអាចត្រូវបានប្រគល់ទៅឱ្យជនណាម្នាក់ ដែលមានការពាក់ព័ន្ធតាមផ្លូវច្បាប់ជាមួយនឹងម្ចាស់រោងចក្រ ឬ អ្នកគ្រប់គ្រងរោងចក្រ ។

ប្រសិនបើលិខិតបញ្ជានៅតែគ្មានអ្នកទទួលជំនួស ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវបិទលិខិតបញ្ជានោះនៅច្រកចូល ឬ មាត់ទ្វាររោងចក្រ ឬ នៅគេហដ្ឋានរបស់ម្ចាស់រោងចក្រ ឬ អ្នកគ្រប់គ្រងរោងចក្រនោះ ដោយមានវត្តមានរបស់អាជ្ញាធរ ឬ ភ្នាក់ងារនគរបាលជាសាក្សី ។

ក្រោយពីបានប្រតិបត្តិដូចបានចែងក្នុងកថាខណ្ឌខាងលើ លិខិតបញ្ជាត្រូវបានចាត់ទុកថាបានទទួលដោយម្ចាស់រោងចក្រ ឬ អ្នកគ្រប់គ្រងរោងចក្រ ។

**មាត្រា ៤១.-**

ក្នុងករណីដែលមានឧប្បត្តិហេតុ ឬ គ្រោះថ្នាក់នៅក្នុងរោងចក្រ ដែលបណ្តាលឱ្យរោងចក្រត្រូវផ្អាកដំណើរការទាំងស្រុងលើសពី ៧ (ប្រាំពីរ)ថ្ងៃ ម្ចាស់រោងចក្រ ឬ អ្នកគ្រប់គ្រងរោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងរយៈពេល ១០ (ដប់)ថ្ងៃ យ៉ាងយូរបន្ទាប់ពីថ្ងៃកើតហេតុនោះ ។

ពេលដែលមានឧប្បត្តិហេតុ ឬ គ្រោះថ្នាក់កើតឡើងដូចខាងលើ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវធ្វើអធិការកិច្ចរោងចក្រហើយអនុវត្តតាមមាត្រា ៣៧ ឬ មាត្រា ៣ កថាខណ្ឌទី ១ ប្រសិនបើចាំបាច់ ។

15/20

**មាត្រា ៤២.-**

ក្នុងការចុះធ្វើអធិការកិច្ច មន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលត្រូវបង្ហាញប័ណ្ណសម្គាល់ខ្លួន និងលិខិតបញ្ជាបេសកកម្ម ជូនទៅម្ចាស់រោងចក្រ ឬ ជនដែលខ្លួនត្រូវទំនាក់ទំនង ។

ការធ្វើអធិការកិច្ចរោងចក្រ ត្រូវមានកំណត់ហេតុត្រឹមត្រូវ និងច្បាស់លាស់ ។

## ជំពូកទី ៦
## ទោសប្បញ្ញត្តិ

**មាត្រា ៤៣.-**

ម្ចាស់សិប្បកម្មណា ដែលពុំបានធ្វើការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអាជ្ញាធរមូលដ្ឋាន និងធ្វើការចុះបញ្ជីនៅមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្ត-ក្រុង ដែលខ្លួនបានបោះទីតាំងដូចកំណត់ក្នុងមាត្រា ២៣ វាក្យខ័ណ្ឌទី ១ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥០០.០០០រៀល (ប្រាំរយពាន់រៀល) ទៅ ២.៥០០.០០០រៀល (ពីរលានប្រាំរយពាន់រៀល) ។

ជនណាបង្កើតប្រភេទសិប្បកម្ម ដែលមានចែងដោយប្រកាសរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដូចក្នុងមាត្រា ២៣ ដោយគ្មានការអនុញ្ញាត ឬ ល្មើសនឹងមាត្រា ២៣ ឬ បទប្បញ្ញត្តិដទៃទៀតពាក់ព័ន្ធនឹងមាត្រា ២៣ វាក្យខ័ណ្ឌទី ២ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០រៀល (មួយលានរៀល) ទៅ ៥.០០០.០០០រៀល(ប្រាំលានរៀល) ។

**មាត្រា ៤៤.-**

ម្ចាស់រោងចក្រណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ១១ មាត្រា ១៣ មាត្រា ១៤ មាត្រា ១៥ វាក្យខ័ណ្ឌទី ១ មាត្រា ១៦ មាត្រា ១៧ មាត្រា ១៨ មាត្រា ៤១ វាក្យខ័ណ្ឌទី ១ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២.០០០.០០០រៀល (ពីរលានរៀល) ទៅ ១០.០០០.០០០រៀល (ដប់លានរៀល) ។

**មាត្រា ៤៥.-**

ម្ចាស់រោងចក្រណា ដែលប្រព្រឹត្តល្មើសនឹងមាត្រា ២៤ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០.០០០រៀល (ប្រាំលានរៀល) ទៅ ២៥.០០០.០០០រៀល (ម្ភៃប្រាំលានរៀល) ។

ប្រសិនបើមានគ្រោះថ្នាក់ ដែលបណ្តាលមកពីការប្រព្រឹត្តល្មើសនឹងមាត្រាខាងលើ ម្ចាស់រោងចក្រត្រូវទទួលសំណងខូចខាតទាំងអស់ដល់ជនរងគ្រោះ ។ ក្នុងករណីនេះ មន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវកសាងសំណុំរឿងបញ្ជូនទៅតុលាការ ដើម្បីវិនិច្ឆ័យទោសតាមច្បាប់ ។

**មាត្រា ៤៦.-**

ម្ចាស់រោងចក្រណា ដែលប្រព្រឹត្តល្មើសនឹងមាត្រា ២៦ មាត្រា ២៧ មាត្រា ២៨ មាត្រា ២៩ និងមាត្រា ៣០ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២.០០០.០០០ រៀល (ពីរលានរៀល) ទៅ ១០.០០០.០០០រៀល (ដប់លានរៀល) ។

ក្នុងករណីបទល្មើសនេះបង្កឱ្យមានគ្រោះថ្នាក់ដល់មនុស្ស ឬ អន្តរាយដល់ទ្រព្យសម្បត្តិក្នុង ឬ ក្រៅរោងចក្រ មន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវកសាងសំណុំរឿងបញ្ជូនទៅតុលាការ ដើម្បីសម្រេចអំពីសំណងអន្តរាយទៅតាមល្មើសទ-កម្ម និងផ្តន្ទាទោសតាមច្បាប់ ។

**មាត្រា ៤៧.-**

ជនណាដែលមិនផ្តល់ ឬ ផ្តល់របាយការណ៍មិនពិត ឬ ប្រព្រឹត្តល្មើសនឹងមាត្រា ១៩ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួនពី ១០.០០០.០០០រៀល (ដប់លានរៀល) ទៅ ៥០.០០០.០០០រៀល (ហាសិបលានរៀល) និងផ្តន្ទាទោសតាមច្បាប់ដូចមានចែងក្នុងច្បាប់ព្រហ្មទណ្ឌ ។

**មាត្រា ៤៨.-**

ជនណាដែលដំណើរការរោងចក្រ ដោយប្រព្រឹត្តល្មើសនឹងមាត្រា ៣៨ វាក្យខណ្ឌទី ១ និងមាត្រា ៣៩ វាក្យខណ្ឌទី ១ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២០.០០០.០០០

រៀល (ម្ភៃលានរៀល) ទៅ ១០០.០០០.០០០រៀល (មួយរយលានរៀល)ឬ/និងទោសដាក់ពន្ធនាគារពី ៦ ខែ ទៅ ១ ឆ្នាំ ។

ក្នុងករណីដែលការប្រព្រឹត្តល្មើសនឹងមាត្រា ៣៩ វាក្យខ័ណ្ឌទី ៣ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៣០.០០០.០០០រៀល (សាមសិបលានរៀល) ដល់ ១៥០.០០០.០០០ រៀល (មួយរយហាសិបលានរៀល) ឬ/និងទោសដាក់ពន្ធនាគារពី ១ ឆ្នាំ ទៅ ៣ ឆ្នាំ ។

**មាត្រា ៤៩.-**

ជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៤ មាត្រា ៩ និងមាត្រា ២០ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០.០០០.០០០រៀល (ដប់លានរៀល) ទៅ ៥០.០០០.០០០រៀល (ហាសិបលានរៀល) ។

ក្នុងករណីបទល្មើសនេះបណ្តាលឱ្យមានគ្រោះថ្នាក់ដល់មនុស្ស ឬ អន្តរាយទ្រព្យសម្បត្តិក្នុង ឬ ក្រៅរោងចក្រ មន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវកសាងសំណុំរឿងបញ្ជូនទៅតុលាការ ដើម្បីសម្រេចអំពីសំណងអន្តរាយទៅតាមលទ្ធកម្ម និងផ្តន្ទាទោសតាមច្បាប់ ។

**មាត្រា ៥០.-**

ម្ចាស់រោងចក្រណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ១០ និងមាត្រា ២៥ នៃច្បាប់នេះ ត្រូវទទួលទោស និងសំណងតាមច្បាប់ស្តីពីការងារ ។

**មាត្រា ៥១.-**

ម្ចាស់រោងចក្រណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៣១ មាត្រា ៣២ និងមាត្រា ៣៣ នៃច្បាប់នេះ ត្រូវទទួលទោស និងសំណងតាមច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ។

**មាត្រា ៥២.-**

មន្ត្រីមានសមត្ថកិច្ចណា ដែលបានប្រព្រឹត្តល្មើសនឹងមាត្រា ៨ វាក្យខ័ណ្ឌទី ១ និងមាត្រា ២១ នៃច្បាប់នេះ ត្រូវទទួលទណ្ឌកម្មរដ្ឋបាល តាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ឬ ផ្តន្ទាទោសពិន័យជាប្រាក់ពី ២.០០០.០០០រៀល (ពីរលានរៀល) ទៅ

១០.០០០.០០០ រៀល (ដប់លានរៀល) និងផ្តន្ទាទោសដាក់ពន្ធនាគារពី ០៦ ខែ ទៅ ១ ឆ្នាំ ឬ ទោសណាមួយ ។

**មាត្រា ៥៣.-**

ជនណាដែលរារាំង ប្រឆាំងនឹងការអនុវត្តច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួនពី ២.០០០.០០០រៀល (ពីរលានរៀល) ទៅ ១០.០០០.០០០រៀល (ដប់លានរៀល) និងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារចំនួនពី ១ ខែ ទៅ ៦ ខែ ។

**មាត្រា ៥៤.-**

ចំពោះជនណាដែលបានប្រព្រឹត្តបទល្មើសហើយពុំរាងចាល ត្រូវផ្តន្ទាទោសទ្វេជាពីរតាមបទល្មើសនៃមាត្រានីមួយៗក្នុងជំពូកនេះ ។

**មាត្រា ៥៥.-**

ទោសទណ្ឌទាំងឡាយណាដែលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥០០.០០០រៀល(ប្រាំរយពាន់រៀល) ទៅ ១០.០០០.០០០រៀល (ដប់លានរៀល) មន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល មានសិទ្ធិពិន័យអន្តរការណ៍ ។

ក្នុងករណីរឹងរូស មិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវកសាងសំណុំរឿងបញ្ជូនទៅតុលាការ ។

## ជំពូកទី ៧
## អន្តរប្បញ្ញត្តិ

**មាត្រា ៥៦.-**

ក្រោយពីច្បាប់នេះចូលជាធរមាន រោងចក្រ សិប្បកម្មទាំងអស់ ដែលបានបង្កើតរួចហើយ និងមិនទាន់មានប្រកាសបង្កើតរោងចក្រ ឬ លិខិតអនុញ្ញាត ឬ មិនគាន់បានចុះបញ្ជីត្រូវមកបំពេញសំណុំបែបបទឱ្យស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ នៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឬ នៅមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្ត-ក្រុង ដែលសិប្បកម្មពោះ

ទីតាំងក្នុងរយៈពេល ៦ (ប្រាំមួយ)ខែ យ៉ាងយូរ ។ ក្នុងករណីចាំបាច់ រយៈពេលនេះអាចបន្តបាន ៣(បី)ខែ បន្ថែម ។

## ជំពូកទី ៨

## អវសានប្បញ្ញត្តិ

**មាត្រា ៥៧.-**

បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៦

នស/រកម.០៦០៦.០២៤

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**

**ហត្ថលេខា**

**ស៊ុយ សែម**

លេខ ៧៦៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០០៦

អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី

យុន ជិនកេន

120